## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ២៤៣ "ក្រ.វ"

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

សំណុំរឿងព្រហ្មទណ្ឌលេខ៤៦០២

ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

ស៊ើបសួរលេខ៣៦៨៤

ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

ជំនុំជំរះលេខ១២៦

ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ០២និង ០០នាទីរសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកអនុប្រធាន [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦០២ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករលើកអីវ៉ាន់ កម្រិតវប្បធម៌រៀនថ្នាក់ទី៥ ទីកន្លែងកំណើត [redacted] ខេត្តស្វាយរៀង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវមិនចាំលេខ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ហេង "រស់" ម្តាយឈ្មោះ [redacted] ចឹប "ស្លាប់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៩៦៧ "ឌ" ដ.ឃ.ជ ចុះថ្ងៃទី២៥-១០-២០២៣។ (ម១)

២-ឈ្មោះ [redacted] ដាវ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ខែកក្កដា ឆ្នាំ២០០៥ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌រៀនថ្នាក់ទី៦ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវលេខ២៦១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] បុត្រ "រស់" ម្តាយឈ្មោះ [redacted] វ៉ាន់ធុល "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៤០៨ "ឌ" ដ.ឃ.ជ ចុះថ្ងៃទី០៨-១១-២០២៣។(ម១)

៣-ឈ្មោះ [redacted] ដាវ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មកររោងចក្រ កម្រិតវប្បធម៌រៀនថ្នាក់ទី៥ ទីកន្លែងកំណើត [redacted] ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវវេងស្រេង សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះគា "រស់" ម្តាយឈ្មោះ ហេង "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៥៣៧ "ឌ" ដ.ឃ.ជ ចុះថ្ងៃទី១៣-១១-២០២៣។(ម១)

ជាប់ចោទពីបទលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១២$E_0$ ផ្លូវម៉ៅសេទុងសង្កាត់/



Scanned with CamScanner

ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០២៣ វេលាម៉ោងប្រហែល១២ និង៣០នាទី នៅចំណុចមុខផ្ទះលេខ១១២E₀ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានករណី លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ) បង្កឡើងដោយជនជាប់ចោទចំនួន ០៥នាក់ មានឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៨ឆ្នាំ ឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥,ឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ,ឈ្មោះ ផាន់ណា ភេទប្រុស អាយុប្រហែល១៧ឆ្នាំ និងបក្ខពួកមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល១៧ឆ្នាំ ជនជាតិខ្មែរ។ ដោយមុនពេលកើតហេតុជនជាប់ចោទទាំង០៥នាក់បានមកជួបជុំគ្នាដើម្បីចេញធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ លុះជិះមកដល់ចំណុចកើតហេតុខាងលើ ក៏ឃើញស្ត្រីជាជនរងគ្រោះកំពុងជិះម៉ូតូម្នាក់ឯងនិយាយទូរស័ព្ទ ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] វិសាល បើកម៉ូតូចូលទៅជិត ហើយឈ្មោះ [redacted] ដារ៉ាត់ បានធ្វើសកម្មភាពឆក់យកទូរស័ព្ទពីជនរងគ្រោះបានសម្រេច រួចជិះគេចខ្លួន ចំណែកបក្ខពួកផ្សេងទៀតជិះម៉ូតូពីក្រោយបិទគូថរួចនាំគ្នាគេចខ្លួនអស់។លុះដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង១៤ និង២០នាទី កម្លាំងសមត្ថកិច្ចការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានស្រាវជ្រាវឈានដល់ការឃាត់ខ្លួនជនជាប់ចោទចំនួន០៣នាក់ មានឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] ដារ៉ាត់ និងឈ្មោះ [redacted] ដារ៉ា ដែលពាក់ព័ន្ធនឹងបទល្មើសជាក់ស្តែងពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្ត អំពើហិង្សា (ឆក់ទូរស័ព្ទដៃ) កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ប្រព្រឹត្តចំណុចមុខផ្ទះលេខ២៤៧ ផ្លូវលេខ១៥០ ក្រុមទី២៩ ភូមិ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ក្រោយពីបានធ្វើការសាកសួរ ជនជាប់ចោទខាងលើបានឆ្លើយសារភាពប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ នៅចំណុចមុខផ្ទះលេខ១១២E₀ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ពួកខ្លួនពិតជាបានធ្វើសកម្មភាពលួចមានស្ថានទម្ងន់ទោស(ឆក់ទូរស័ព្ទដៃ)មួយគ្រឿងម៉ាកអាយហ្វូន១១ ពណ៌ក្រហម ពិតមែននិងបានយកទូរស័ព្ទទៅលក់ឱ្យឈ្មោះ ប្រាក់ គឹមផល្លា ភេទប្រុស អាយុប្រហែល៣៥ឆ្នាំ នៅម្តុំផ្សារទួលទំពូងបានប្រាក់៦០ (ហុកសិប) ដុល្លារអាមេរិក រួចយកប្រាក់មកចែកគ្នាបានម្នាក់១៥(ដប់ប្រាំ)ដុល្លារអាមេរិក ។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿង និងបញ្ជូនជនជាប់ចោទមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមនីតិវិធី។ ចំណែកឈ្មោះ [redacted] ណា ភេទប្រុស,ជនមិនស្គាល់ឈ្មោះភេទប្រុស និងឈ្មោះ [redacted] គឹមផល្លា ភេទប្រុស គេចខ្លួន។

-បានឃើញ៖របាយការណ៍សំយោគលេខ២៨៥/២០២៣រ.ប.ក ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០២៣របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៤៩០អ.យ.ឧ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២៣របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសន្និដ្ឋានស្ថាពរលេខ ៤៧៦៩ អ.យ.ឧ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ របស់តំណាង



Scanned with CamScanner

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ៖ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦១៤៩ "ខ" ដ.ដ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វិសាល បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង២ រសៀល ខ្ញុំបានជិះម៉ូតូចំនួន០១គ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ ពាក់ផ្លាកលេខ ភ្នំពេញ 1JM-9855 ឌុបឈ្មោះ [redacted] ដាវ៉ាត់ ភេទប្រុសនិងឈ្មោះ [redacted] ដាវ៉ា ទៅជួបជុំគ្នានៅស្ថានីយ៍ប្រេងឥន្ធនៈកាល់តិច វិទ្យាល័យជាស៊ីមសាមគ្គី ដើម្បីជួបឈ្មោះ ផាន់ណា ភេទប្រុស និងឈ្មោះ ដាប ភេទប្រុស ក៏បានពិភាក្សាគ្នាក្នុង គោលបំណងទៅម្តុំកោះពេជ្រ ដោយខ្ញុំជាអ្នកបើកម៉ូតូម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ឌុបឈ្មោះ [redacted] ដាវ៉ាត់ ភេទប្រុស ចំណែកឈ្មោះ ផាន់ណា ភេទប្រុស ជិះម៉ូតូមួយគ្រឿងម៉ាកស៊ុយហ្ស៊ូគីនិច ពណ៌ស ស៊េរីឆ្នាំ២០២៣ ឌុបមនុស្សប្រុសម្នាក់ទៀតដែលខ្ញុំមិនស្គាល់ឈ្មោះ, ឈ្មោះ ដាប ភេទប្រុស ឌុបមិត្តភក្តិវាដែរខ្ញុំមិនស្គាល់ឈ្មោះ និងឈ្មោះ [redacted] ដាវ៉ា ជិះម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២៣ មិនចាំផ្លាកលេខក៏ជិះតាម ផ្លូវម៉ៅសេទុង ប្រទះឃើញមនុស្សស្រីម្នាក់ជិះម៉ូតូកំពុងនិយាយទូរស័ព្ទ ហើយខ្ញុំបានជិះម៉ូតូទៅអែបខាងស្តាំដៃ ម៉ូតូរបស់នារីជនរងគ្រោះរួចហើយឈ្មោះ [redacted] ដាវ៉ាត់ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីនារីរងគ្រោះបាន សម្រេចរួចជិះគេចខ្លួន។ ចំពោះឈ្មោះ ផាន់ណា ឈ្មោះ [redacted] ដាវ៉ា និងអ្នកផ្សេងទៀតជិះបិទគូថពីក្រោយ។

-ជនជាប់ចោទឈ្មោះ [redacted] ដាវ៉ាត់ បានឆ្លើយថា៖ កាលពីថ្ងៃ១៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងមិនចាំ ឈ្មោះស៊ុន វិសាល ជិះម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ មកឌុបខ្ញុំនៅម្តុំបឹងសាឡាង ខណ្ឌទួលគោក ដើម្បីទៅជួបជុំគ្នានៅម្តុំវិទ្យាល័យជាស៊ីមសាមគ្គី ហើយក៏បបួលគ្នាទៅម្តុំកោះពេជ្រជិះម៉ូតូប៉ុន្មាន គ្រឿងខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំជិះម៉ូតូជាមួយឈ្មោះ មូនី ដាវ៉ា គឺម៉ូតូ០១គ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ។ ចំណែក ឈ្មោះ [redacted] វិសាល ជិះជាមួយអ្នកណាខ្ញុំពុំដឹងទេ។ ចំពោះឈ្មោះ [redacted] វិសាល ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពី ជនរងគ្រោះមនុស្សស្រីបានសម្រេច យ៉ាងណាខ្ញុំក៏ពុំបានដឹងដែរដោយខ្ញុំនឹងឈ្មោះ [redacted] ដាវ៉ា ជិះទៅកោះពេជ្រ មុន។ ក្នុងពេលដែលឈ្មោះ [redacted] វិសាល ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃបានសម្រេចគឺយកទៅលក់ភាគច្រើននៅ ផ្សារទួលទំពូងបានប្រាក់ប៉ុន្មានខ្ញុំពុំដឹងទេ ហើយខ្ញុំក៏ពុំបានប្រាក់ក្នុងការឆក់ទូរស័ព្ទដៃនេះដែរ។

-ជនជាប់ចោទឈ្មោះ [redacted] ដាវ៉ា បានឆ្លើយថា៖ កាលពីថ្ងៃ១៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងមិនចាំ ឈ្មោះ [redacted] វិសាល ជិះម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ ឌុបឈ្មោះ [redacted] ដាវ៉ាត់ ចំណែកឯឈ្មោះ ផាន់ណា ភេទប្រុស ជិះម៉ូតូមួយគ្រឿងម៉ាកស៊ុយហ្ស៊ូគីនិច ពណ៌ខៀវលាយពណ៌ស ស៊េរីឆ្នាំ ២០២៣ ឌុបមនុស្សប្រុសម្នាក់ទៀតមិនស្គាល់ឈ្មោះ និងខ្ញុំ ជិះម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២៣ មិនចាំផ្លាកលេខមកជួបជុំគ្នានៅម្តុំវិទ្យាល័យជាស៊ីមសាមគ្គី ក្នុងគោលបំណងទៅដើរលេងម្តុំ កោះពេជ្រ ពួកខ្ញុំជិះម៉ូតូមកដល់ម្តុំទួលទំពូង ឈ្មោះ ផាន់ណា បានប្រទះឃើញមនុស្សស្រីជិះម៉ូតូតាមផ្លូវ កំពុង និយាយទូរស័ព្ទ ហើយឈ្មោះ ផាន់ណា ក៏បានប្រាប់ឈ្មោះ [redacted] វិសាល ឱ្យធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរង គ្រោះបានសម្រេច ហើយចំណែកខ្លួនបានជិះម៉ូតូពីក្រោយ។ ខ្ញុំមិនដឹងថាឈ្មោះ [redacted] វិសាល ធ្វើសកម្មភាពឆក់ ទូរស័ព្ទដៃរបស់គេទេ។ ឈ្មោះ [redacted] វិសាល, ឈ្មោះ [redacted] ដាវ៉ាត់, ឈ្មោះ ផាន់ណា បានយកទូរស័ព្ទដៃដែលឈ្មោះ [redacted] វិសាល ឆក់ពីជនរងគ្រោះទៅលក់នៅកន្លែងណានោះ ខ្ញុំពុំដឹងទេ គ្រាន់តែដឹងថាឈ្មោះ [redacted] វិសាល បាន ឱ្យប្រាក់មកខ្ញុំចំនួន ១០.០០០០(ដប់ម៉ឺន)រៀល តែប៉ុណ្ណោះ។ ខ្ញុំស្គាល់ឈ្មោះ [redacted] ដាវ៉ាត់ យូរមកហើយគឺមានរ យៈពេលជិតមួយឆ្នាំ ចំណែកឈ្មោះ [redacted] វិសាល និងឈ្មោះផាន់ណា ខ្ញុំទើបតែស្គាល់បានរយៈពេល២ឬ៣ខែ ទេ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ



Scanned with CamScanner

ទាំងបីនាក់តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ជនជាប់ចោទទាំងបីនាក់ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដែលស្តែងឱ្យឃើញពីចេតនាប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ហេតុដូច្នេះតំណាងអយ្យការធ្វើការសន្និដ្ឋានដោយតម្កល់ការចោទប្រកាន់លើជនជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១២E₀ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារថា៖នាពេលសវនាការកូនក្តីខ្លួនបានឆ្លើយសារភាពថា ទទួលស្គាល់កំហុសរបស់គាត់រួចហើយហើយគាត់សន្យាថាឈប់ប្រព្រឹត្តនិងធ្វើការកែខ្លួនវិញ សូមឱ្យតុលាការបន្ធូរបន្ថយទោសឱ្យដោយកូនក្តីខ្លួនដោយក្តីអនុគ្រោះ។

-ជនជាប់ចោទឈ្មោះ[redacted] វិសាល បាននិយាយសំដីចុងក្រោយបង្អស់ថា៖សុំបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] ដាវ៉ាត់ បាននិយាយសំដីចុងក្រោយបង្អស់ថា៖សុំបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] ដាវ៉ា បាននិយាយសំដីចុងក្រោយបង្អស់ថា៖សុំបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដាវ៉ាត់

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដាវ៉ា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦០២ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦១៤៩ "ខ" ដ.ជ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានបញ្ជូនជនជាប់ចោទ៖

ក-ឈ្មោះ[redacted] វិសាល ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ[redacted] ដាវ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ ជនជាតិខ្មែរ

គ-ឈ្មោះ[redacted] ដាវ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១២E₀ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញកាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង០២រសៀល មានករណីលួចមានស្ថានទម្ងន់ទោសបង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] វិសាល ឈ្មោះ បុត្រ ដាវ៉ាត់ និងឈ្មោះ[redacted] ដាវ៉ា ដែលបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះដែលកំពុងជិះម៉ូតូ លុះពេលធ្វើសកម្មភាពបានសម្រេចជនជាប់ចោទទាំង០៣នាក់បានជិះម៉ូតូគេចខ្លួនបាត់ ចំណែកទូរស័ព្ទត្រូវបានជនជាប់ចោទយកទៅលក់នៅម្តុំផ្សារទួលទំពូង។ ក្រោយមកសមត្ថកិច្ចបានធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា និងបានឃាត់ខ្លួនជនជាប់ចោទចំនួន០៣នាក់ខាងលើមាន



Scanned with CamScanner

ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ និងឈ្មោះ មូនី ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ រួមទាំងវត្ថុតាង ដើម្បីធ្វើការសាកសួរនិងចាត់ការតាមនីតិវិធី។ ក្រោយពេលសាកសួរជនជាប់ចោទបានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ជនរងគ្រោះនិងប្រជាពលរដ្ឋផ្សេងៗទៀត នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញជាច្រើនលើកច្រើនសារពិតមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] វិសាល បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនពិតជាបានជិះម៉ូតូទៅឌុបឈ្មោះ [redacted] ដារ៉ាត់, ឈ្មោះ ផាន់ណា ឌុបមនុស្សម្នាក់ទៀតមិនស្គាល់ឈ្មោះ និងឈ្មោះ [redacted] ដារ៉ា បានជិះម៉ូតូម្នាក់ឯង ក៏បានបបួលគ្នាឆក់ទូរស័ព្ទរបស់ប្រជាពលរដ្ឋ ក្រោយពេលធ្វើសកម្មភាពបានសម្រេចខ្លួនបានយកទៅលក់នៅម្តុំផ្សារទួលទំពូង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននឹងបញ្ជូនមកតុលាការតែម្តង។

៤-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ាត់ បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនបានជិះម៉ូតូជាឈ្មោះ [redacted] ដារ៉ា ហើយឈ្មោះ [redacted] វិសាល ជិះម៉ូតូជាមួយអ្នកណាខ្លួនមិនចាំទេ, ឈ្មោះ ផាន់ណា និងមនុស្សម្នាក់ទៀតមិនស្គាល់ឈ្មោះ ក្នុងគោលបំណងទៅលេងម្តុំកោះពេជ្រ លុះមកដល់ម្តុំទួលទំពូងបានបបួលគ្នាឆក់ទូរស័ព្ទរបស់ប្រជាពលរដ្ឋដើម្បីយកទៅលក់។ ក្រោយពេលធ្វើសកម្មភាពបានសម្រេចខ្លួនបានយកទៅលក់នៅម្តុំផ្សារទួលទំពូងត្រូវបានសមត្ថកិច្ចឃាត់ខ្លួននឹងបញ្ជូនមកតុលាការតែម្តង។

៥-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួននិងបក្ខពួកផ្សេងទៀតពិតជាបានបបួលគ្នាជិះម៉ូតូឆក់ទូរស័ព្ទរបស់ប្រជាពលរដ្ឋ ដើម្បីយកទៅលក់ក្រោយពេលធ្វើសកម្មភាពបានសម្រេចបក្ខពួកខ្លួនបានយកទៅលក់នៅម្តុំផ្សារទួលទំពូង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននឹងបញ្ជូនមកតុលាការតែម្តង។

៦-តាមរបាយការណ៍សំយោគលេខ ២៨៥/២០២៣ រ.ប.ក ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០២៣របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល បានបញ្ជាក់ថាជនសង្ស័យឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៩ឆ្នាំ, ឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ និងឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ ពិតជាបានធ្វើសកម្មភាពប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស នៅចំណុចមុខផ្ទះលេខ១១២$E_0$ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន ។

៧-តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងក្តីមានលក្ខណៈស៊ីសង្វាក់បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៩ឆ្នាំ ឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ ជនជាតិខ្មែរ និងឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស នៅចំណុចមុខផ្ទះលេខ១១២$E_0$ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន ។

៨-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ និងឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ ដែលបានធ្វើសកម្មភាពឆក់ទូរស័ព្ទដែលជាទ្រព្យសម្បត្តិអ្នកដទៃ ដែលបង្កឱ្យមានព្យសនកម្មចេញពីអំពើដោយផ្ទាល់ខ្លួន ដែលអំពើនេះត្រូវបានច្បាប់កំណត់ថាជាបទល្មើស លួចមានស្ថានទម្ងន់ទោស



Scanned with CamScanner

ហើយបញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ។

៩-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយល្អក្នុងសង្គម ដែលច្បាប់ហាមឃាត់ជាពិសេសបំពានទៅនឹងមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១០-ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ជានីតិជននិងជាជនដែលមាននីតិសម្បទាស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១១-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥និងឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ខែមិថុនា ឆ្នាំ២០០៤ ជាអនីតិជន ពុំមានសញ្ញាណាមួយដែលបញ្ជាក់ថា ជនជាប់ចោទមានវិបល្លាសស្មារតីមិនអាចទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្តនោះទេ។

១២-ការលើកឡើងរបស់តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាន នាពេលសវនាការដោយបានលើកឡើងពីពិរុទ្ធភាពបញ្ជាក់លើជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុសកើតថ្ងៃទី២២ខែកក្កដា ឆ្នាំ២០០៥ និងឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរពីបទលួចមានស្ថានទម្ងន់ទោស មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែលគប្បីតុលាការលើកយកមកពិចារណា។

១៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួននោះមានមូលហេតុសមស្របតាមច្បាប់ គប្បីតុលាការនឹងលើកយកមកពិចារណា និងសម្រេច។

១៤-ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ និងឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ បាននិយាយសំដីចុងក្រោយបង្អស់ថាសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផងគប្បីតុលាការពិចារណាលើសំណូមពររបស់ជនជាប់ចោទ។

១៥-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៩ឆ្នាំ ឈ្មោះបុត្រ ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ និងឈ្មោះ [redacted] ដារ៉ា ភេទប្រុសកើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស នៅចំណុចមុខផ្ទះលេខ១១២$E_0$ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១៦-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ាត់ និងជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ជាអនីតិជន ការយល់ដឹងនូវមានកម្រិតនិងមិនអាចស្វែងយល់នូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដូចនេះគប្បីតុលាការលើកយកមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌយកមកអនុវត្តលើអនីតិជនអាយុពី ១៤ឆ្នាំឡើងទៅ។

## ហេតុដូច្នេះសម្រេច

I-ផ្តន្ទាទោសជនជាប់ចោទ៖

ក-ឈ្មោះ [redacted] ដារ៉ាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ។

ខ-ឈ្មោះ [redacted] ដារ៉ា ភេទប្រុស កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)ដាក់ពន្ធនាគារកំណត់ ៣(បី)ឆ្នាំ។

គ-ឈ្មោះ [redacted] វិសាល ភេទប្រុសអាយុ១៩ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)ដាក់ពន្ធនាគារ



Scanned with CamScanner

កំណត់៤(បួន)ឆ្នាំ។

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅនៅចំណុចមុខផ្ទះលេខ១១២E₀ ផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner